00817784

E200/3

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 20 / 06 / 2012
ម៉ោង (Time/Heure): 09:40
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

# អង្គជំនុំជម្រះសាលាដំបូង

**ជូនចំពោះ:** **ភាគីទាំងអស់នៃសំណុំរឿង ០០២** កាលបរិច្ឆេទ: ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១២

**ពី:** **ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង**

**ចម្លងជូន:** **លោក/លោកស្រីចៅក្រមទាំងអស់ និងមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង**

**កម្មវត្ថុ:** **ចម្លើយតបរបស់អង្គជំនុំជម្រះសាលាដំបូងទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាសុំអនុញ្ញាតក្នុងការផ្តល់លិខិតធានាអះអាងអំពីការមិនចោទប្រកាន់ដល់សាក្សីនានា (ឯកសារ** E200)

១. តាមសំណើខាងលើ សហព្រះរាជអាជ្ញាស្នើសុំការអនុញ្ញាតពីអង្គជំនុំជម្រះដើម្បីផ្តល់នូវការធានាចំពោះសាក្សី ដែលថានឹងមិនមានការចោទប្រកាន់ទៅលើសាក្សីនោះទេ ហើយបានភ្ជាប់មកជាមួយនូវលិខិតគំរូនៃការធានាអះអាង (ឧបសម្ព័ន្ធ ក) ផងដែរ។ សហព្រះរាជអាជ្ញាស្នើសុំផ្តល់ការធានាជាលក្ខណៈអភ័យឯកសិទ្ធិដល់សាក្សីទាំងឡាយណាដែលមានការភ័យខ្លាច អំពីលទ្ធភាពដែលអាចមានការចោទប្រកាន់ណាមួយមកលើខ្លួនទាក់ទិននឹងហេតុការណ៍នានាដែលបានកើតឡើងក្នុងអំឡុងថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩ និងដើម្បីជំរុញឲ្យសាក្សីដែលមានការភ័យខ្លាចនោះអាចផ្តល់សក្ខីកម្មបានទូលំទូលាយ និងពិតប្រាកដតាមអ្វីដែលគាត់បានដឹង ។ ឧបសម្ព័ន្ធ "ក" ដែលបានរៀបចំឡើងដោយសហព្រះរាជអាជ្ញា ធ្វើឡើងក្នុងគោលបំណងដើម្បីជូនដំណឹងដល់សាក្សីថា (១)សហព្រះរាជអាជ្ញានៃ អ.វ.ត.ក នឹងមិនផ្តើមការចោទប្រកាន់ណាមួយទៅលើសាក្សី

នោះទេ ហើយ (២)អនុលោមតាមច្បាប់កម្ពុជានាពេលបច្ចុប្បន្ន សាក្សីពុំអាចត្រូវបានចោទប្រកាន់ដោយតុលាការកម្ពុជាណាមួយឡើយ។ សហព្រះរាជអាជ្ញាស្នើថា លិខិតធានាអះអាងនេះគួរតែប្រគល់ទៅឲ្យសាក្សីតាមរយៈអង្គភាពគាំពារសាក្សី និងអ្នកជំនាញ (WESU)។

២. អង្គជំនុំជម្រះសាលាដំបូងគាំទ្រនូវគំនិតផ្តួចផ្តើមរបស់សហព្រះរាជអាជ្ញាក្នុងការផ្តល់នូវការធានាដល់សាក្សី ដែលថានឹងមិនមានការចោទប្រកាន់ទៅលើសាក្សីដោយសហព្រះរាជអាជ្ញានៅចំពោះមុខ អ.វ.ត.ក ហើយអង្គជំនុំជម្រះក៏ឯកភាពផងដែរថា ការផ្តល់ជូននូវការធានានេះគួរធ្វើឡើងតាមរយៈអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ។ ដូចគ្នានេះផងដែរ គំនិតផ្តួចផ្តើមស្រដៀងគ្នានេះក៏បានបង្កើតជាផ្នែកមួយនៃការអនុវត្តរបស់ការិយាល័យរដ្ឋអាជ្ញានៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី (ICTY) ផងដែរ ដែលនៅទីនោះរដ្ឋអាជ្ញាបានផ្តល់នូវការធានាដល់សាក្សីណាដែលរដ្ឋអាជ្ញាមិនមានចេតនាធ្វើការចោទប្រកាន់លើបុគ្គលនេះ។ ទោះបីជាស្របគ្នាជាមួយសេចក្តីសម្រេចរបស់អង្គជំនុំជម្រះលើអញ្ញត្រកម្មរបស់ អៀង សារី ស្តីពីការលើកលែងទោស និងការអនុគ្រោះទោស ចុះថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០១១ (ឯកសារ E51/15) និងសេចក្តីសម្រេចដែលពាក់ព័ន្ធផ្សេងៗទៀត (*ឧទាហរណ៍* សេចក្តីសម្រេចលើអញ្ញត្រកម្មពាក់ព័ន្ធនឹងអាជ្ញាយុកាលនៃបទល្មើសក្រោមច្បាប់ជាតិចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ ឯកសារ E187) ក៏ដោយ តែបើផ្អែកតាមតួនាទីនិងក្របខណ្ឌគតិយុត្តរបស់ អ.វ.ត.ក អង្គជំនុំជម្រះយល់ថា វាជាការមួយពុំសមស្របក្នុងការផ្តល់នូវការធានាអំពីការមិនចោទប្រកាន់នៅចំពោះមុខតុលាការកម្ពុជាផ្សេងទៀតនោះទេ។ អង្គជំនុំជម្រះសូមជូនភ្ជាប់មកជាមួយនូវឧបសម្ព័ន្ធ ក ដែលបានស្នើឡើងដោយហព្រះរាជអាជ្ញា ហើយដែលត្រូវបានកែប្រែដោយអង្គជំនុំជម្រះ។

៣. ប្រសិនបើមេធាវីការពារក្តីជំទាស់ទៅនឹងឧបសម្ព័ន្ធ ក (ដែលអង្គជំនុំជម្រះសាលាដំបូងបានកែប្រែ) មេធាវីការពារក្តីត្រូវបង្ហាញមូលដ្ឋានរបស់ខ្លួនដោយមិនឲ្យហួសពីថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០១២។